# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់**

**និងប្រព័ន្ធយុត្តិធម៌**

**អង្គភាពគ្រប់គ្រងគម្រោង**

**លេខ៖**

# របាយការណ៍ ស្តីពីសកម្មភាពការងារប្រចាំខែ វិច្ឆិកា ឆ្នាំ ២០០៥ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងទិសដៅសម្រាប់អនុវត្តបន្ត

## I.សេចក្តីផ្តើម ៖

នៅខែវិច្ឆិកានេះ ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ បានដំណើរការងាររបស់ខ្លួនស្របតាមបេសកកម្ម ដែលបានកំណត់ក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ហើយសម្រេចបាននូវលទ្ធផលជាក់ស្តែង ដូចខាងក្រោម ៖

## II.ការងារកែទម្រង់ច្បាប់ និងតុលាការ ៖

- ជួបជាមួយ EWMI ពិភាក្សាពីបញ្ហាចុះសិក្សាស្រាវជ្រាវពីជំនួយផ្នែកច្បាប់
- ជួបជាមួយទីប្រឹក្សារបស់ PMU សិក្សាអំពី Milestone Review Workplan និងបកប្រែជាភាសាខ្មែរ នូវ Project Profile , Project Summary & Cheerleader
- បន្តការជួបជាមួយ EWMI ដើម្បីធ្វើពង្រាង TOR និងគម្រោងចុះសិក្សា
- ធ្វើសិក្ខាសាលានៅខេត្តតាកែវ ស្តីពីការផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ស៊ូ គិរិន្ទ** អភិបាល ខេត្តតាកែវ

- ធ្វើសិក្ខាសាលានៅខេត្តកំពតស្តីពីការផ្សព្វផ្សាយកម្មវិធីសកម្មភាព សម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃទី១០ ខែវិច្ឆិកា ឆ្នាំ២០០៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ពុធ ចិន្តារិទ្ធ** អភិបាលខេត្តកំពត និងឯកឧត្តម **ចាន់ សំអាន** អភិបាលក្រុងកែប
- ប្រជុំជាមួយ EWMI ស្តីពីការអនុមត័ធ្វើរបៀបវារៈ នៅថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ ២០០៥
- ប្រជុំ PCB ស្តីពីការបង្ហាញជូនពីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការនៅថ្ងៃទី ២៤ ខែ វិច្ឆិកា ឆ្នាំ ២០០៥ ក្រោមអធិបតីភាពរបស់ ឯកឧត្តម **ស៊ុំ ម៉ានិត**
- ចុះអនុស្សរណៈស្តីអំពីកិច្ចសហប្រតិបត្តិការរវាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័តុលាការ និង EWMI នៅថ្ងៃទី ២៥ ខែ វិច្ឆិកា ឆ្នាំ ២០០៥
- ធ្វើសិក្ខាសាលានៅខេត្តកំពង់ស្ពឺ ស្តីពីការផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម **ចាប ញ៉ាលីខុន្ត** ខេត្តកំពង់ស្ពឺ
- ធ្វើសិក្ខាសាលានៅក្រុងព្រះសីហនុ ស្តីពីការផ្សព្វផ្សាយកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ កាលពីថ្ងៃទី ០៣ ខែវិច្ឆិកា ឆ្នាំ២០០៥ ក្រោមអធិបតីភាពរបស់ឯកឧត្តម **សាយ ហាក់** អភិបាលក្រុងព្រះសីហនុ

## III. **ការស្រាវជ្រាវ** ៖

- តាមដានប្រមូលផ្តុំគំនិត និងស្រាវជ្រាវឯកសារផ្សេងៗ ដែលទាក់ទងនឹងការផ្តល់លទ្ធភាពឱ្យទទួលបានព័ត៏មានអំពីច្បាប់ និងតុលាការឱ្យកាន់តែប្រសើរឡើង
- រៀបចំ និងចងក្រងឯកសារផ្សេងៗដែលចាំបាច់ក្នុងការរៀបចំគម្រោង។

## IV. **ផ្សេងៗ** ៖

- ចូលរួមប្រជុំអន្តរក្រសួង។

## V. **សេចក្តីសន្និដ្ឋាន**

## VI. **ទិសដៅសម្រាប់អនុវត្តក្នុងខែបន្ត**

- ទំនាក់ទំនងស្វែងរកអ្នកឧបត្ថម្ភសម្រាប់អនុវត្តគម្រោងកំណែទម្រង់ច្បាប់ និងតុលាការតាមបញ្ជី ដែលបានរៀបចំរួច

- បន្តប្រជុំក្រុមការងារបច្ចេកទេសចម្រុះរវាងតំណាងរាជរដ្ឋាភិបាល និងតំណាងសហគមន៍ផ្តល់ជំនួយអំពីកិច្ចសហប្រតិបត្តិការខាងផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីបំពេញកាតព្វកិច្ចតាមសូចនាករតាមដានរួមដែលបានកំណត់ដោយកិច្ចប្រជុំពិគ្រោះយោបល់កាលពីថ្ងៃទី ០៦-០៧ ខែធ្នូ ឆ្នាំ២០០៤
- បន្តពង្រឹងសមត្ថភាពរបស់អង្គភាពគ្រប់គ្រងគម្រោង (PMU) ដើម្បីធ្វើឱ្យការអនុវត្តកម្មវិធីសកម្មភាពនៃកំណែទម្រង់មានដំណើរលូន និងពេញលេញដូចដែលបានគ្រោងទុក។

*ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៥*

អ្នកធ្វើរបាយការណ៍

**បានឃើញ និងឯកភាព**

ប្រធាន អ.គ.គ

សេង វ៉ាន់ដា

ស៊ុយ ម៉ុងលាង